01038568

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: A ១៥៧/២/១/២

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ១៣)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម នេយ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
21 / 11 / 2014
ម៉ោង (Time/Heure): 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤

---

**សាធារណៈ (សំណៅកោសល្លុប)**

**ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះសេចក្តីសម្រេចបដិសេធពាក្យសុំរបស់គាត់ស្នើសុំសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះ ស្នើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ**

---

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តី</u>** [redacted]

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ុវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Herve DIAKIESE

Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Martine JACQUIN
Emmanuel JACOMY
Beini YE
François GAUTRY
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះសេចក្តីសម្រេចបដិសេធពាក្យសុំរបស់គាត់ ស្នើសុំសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ" ដែលបានដាក់ដោយមេធាវីការពារក្តី នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដែលបានធ្វើឱ្យមានកិច្ចស៊ើបសួរទៅលើ ក្នុងចំណោមប្រការផ្សេងទៀត ឧក្រិដ្ឋកម្មនានាដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវ[2]។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ និងនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនពីរ ដែលចោទប្រកាន់អំពីឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលម្ចាស់បណ្តឹងឧទ្ធរណ៍អាចមានការទទួលខុសត្រូវផងដែរ[3]។

2. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ និងថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ អង្គភាពគាំពារការការពារក្តី ("អ.គ.ក") បានស្នើសុំការអនុញ្ញាតឱ្យមានការចូលពិនិត្យមើលសំណុំរឿងសម្រាប់ជនសង្ស័យក្នុងសំណុំរឿង ០០៣ និង ០០៤ និងផ្តល់សិទ្ធិផ្នែកនីតិវិធីផ្សេងៗទៀត ដូចមានចែងនៅក្នុងវិធាន

---

[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះសេចក្តីសម្រេចបដិសេធពាក្យសុំរបស់គាត់ស្នើសុំសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ A157/2/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ D65 និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191។

៥៥(៨), ៥៥(១០) និង ២១ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង")[4]។ នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ចៅក្រម យូ ប៊ុនឡេង និងចៅក្រម BLUNK) បានបដិសេធមិនអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងឡើយ ដោយសារតែសហចៅក្រមស៊ើបអង្កេត*យល់ឃើញថា ជនសង្ស័យមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីទេ ពីព្រោះពួកគាត់មិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ*[5]។

3. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង (ចៅក្រម Kasper-Ansermet) បានចេញការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ ដែលនៅក្នុងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានជូនដំណឹងដល់ [redacted] ថា គាត់ត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៤ ("ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង")[6]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ក៏បានជូនដំណឹងដល់ [redacted] ផងដែរថា អនុលោមតាមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង គាត់មានសិទ្ធិមួយចំនួន រួមមាន សិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤ (អនុវត្តស្រដៀងគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១) និងវិធាន ៥៨ *លើកលែងតែបញ្ញត្តិនៃវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក*)[7]។ នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដែលនៅក្នុងនោះគាត់បានជូនដំណឹងដល់សាធារណជនថា ជនសង្ស័យ រួមទាំង [redacted] ត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង[8]។

---

[4] លិខិតពីប្រធាន អ.គ.ក ផ្ញើជូនសហចៅក្រមស៊ើបអង្កេត មានចំណងជើងថា "លិខិតរបស់ អ.គ.ក ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤" ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D4.1.29។ លិខិតរំលឹករបស់ អ.គ.ក ស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ A1/1។

[5] លិខិតពីសហចៅក្រមស៊ើបអង្កេត ផ្ញើជូនប្រធាន អ.គ.ក មានចំណងជើងថា "ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤" ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D4.1.31។

[6] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D109 កថាខណ្ឌ ១។

[7] *ដូចយោងខាងលើ* កថាខណ្ឌ ៤។

[8] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង" ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ អាចរកមើលបាននៅគេហទំព័រ http://www.eccc.gov.kh/sites/default/files/media/ECCC%20IntOCIJ%204%20May%202012En-corrected.pdf ។

4. នៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤ សហមេធាវីរបស់ [redacted] លោក សូ មូស្សេទ្ធី និងលោកស្រី TOMANOVIĆ បានដាក់ជូន ក.ស.ច.ស នូវសំណើជាបន្ទាន់មួយសុំចូលពិនិត្យមើលសំណុំរឿង ០០៤ និងចូលរួមក្នុងកិច្ចស៊ើបសួរ ("សំណើជាបន្ទាន់")[9]។

5. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្ដីជូនដំណឹងមួយទាក់ទងនឹងសំណើជាបន្ទាន់របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ("សេចក្ដីជូនដំណឹងពន្យារពេល")[10]។ នៅក្នុងសេចក្ដីជូនដំណឹងពន្យារពេល ដែលមានការប្រាប់ឱ្យដឹងថា ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានអនុញ្ញាតឱ្យជនសង្ស័យ *ក្នុងចំណោមប្រការផ្សេងទៀត* ចូលពិនិត្យមើលសំណុំរឿង ០០៤ នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍អំពីគោលបំណងពិចារណាឡើងវិញ លើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ទាក់ទិនតែនឹងបញ្ហានេះប៉ុណ្ណោះ[11] ហើយដោយសារតែផ្នែកនេះនៃការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ជាប់ពាក់ព័ន្ធនឹងសំណើជាបន្ទាន់នោះ ពន្យារពេលចេញដីកាសម្រេចលើសំណើជាបន្ទាន់ រហូតដល់ទទួលបានសេចក្ដីសន្និដ្ឋានរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងភាគីនានា ទាក់ទិននឹងការពិចារណាឡើងវិញលើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង[12]។

6. នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤ សហមេធាវី បានដាក់ជូនសហចៅក្រមស៊ើបអង្កេតនូវសារណារបស់លោក [redacted] ស្ដីពីការពិចារណាសាជាថ្មីទៅលើសេចក្ដីសម្រេចក្នុងការអនុញ្ញាតឱ្យលោក [redacted] ចូលពិនិត្យមើលសំណុំរឿង ("សារណាស្ដីពីការពិចារណាសាជាថ្មី")[13]។ សហមេធាវីលើកទឡ្ហីករណ៍ថា ពុំមានមូលដ្ឋានគតិយុត្តិណាមួយក្នុងការពិចារណាសាជាថ្មី លើការ

---

[9] សំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D186។

[10] សេចក្ដីជូនដំណឹង ទាក់ទងនឹងសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D186/1។

[11] *ដូចយោងខាងលើ* កថាខណ្ឌ ១, ៧។

[12] *ដូចយោងខាងលើ* ទំព័រ ៤។

[13] សារណារបស់លោក [redacted] ស្ដីពីការពិចារណាសាជាថ្មីទៅលើសេចក្ដីសម្រេចក្នុងការអនុញ្ញាតឱ្យលោក [redacted] ចូលពិនិត្យមើលសំណុំរឿង ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D186/2។

ចូលពិនិត្យមើលសំណុំរឿងឡើយ[14]។ ទីពីរ សហមេធាវីយល់ឃើញថា [redacted] គួរតែមានសិទ្ធិដូចគ្នាទៅនឹងជនត្រូវចោទដែរ[15] ហើយថា ការបដិសេធមិនឱ្យចូលពិនិត្យមើលសំណុំរឿងរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[16]។ *លើសពីនេះទៀត សហមេធាវីបានស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ មួយផ្នែក ដែលធ្វើឡើងប្រឆាំងនឹងរូបគាត់ក្នុងអំឡុងពេលដែលគាត់ពុំមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង*[17]។

7. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ សហមេធាវីបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនូវពាក្យសុំមួយដែលនៅក្នុងពាក្យសុំនោះ សហមេធាវីបានស្នើឱ្យសហចៅក្រមស៊ើបអង្កេត *ប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ដោយលើកទឡ្ហីករណ៍ថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលទៅលើ* [redacted] *ឡើយ* ("ពាក្យសុំ")[18]។

8. នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចលើសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ("ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង")[19]។ នៅក្នុងដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*បានប្រកាសថា* [redacted] *មិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីទេ ដូច្នេះសំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង ត្រូវបានបដិសេធ*[20] ។ ដោយផ្អែកទៅលើមូលដ្ឋានដូចគ្នានេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញ

---

[14] *ដូចយោងខាងលើ* កថាខណ្ឌ ៩-១៧។

[15] *ដូចយោងខាងលើ* កថាខណ្ឌ ១៨-២៧។

[16] *ដូចយោងខាងលើ* កថាខណ្ឌ ១៨-២៧។

[17] *ដូចយោងខាងលើ* កថាខណ្ឌ ១៨-២៧។

[18] ពាក្យសុំរបស់ [redacted] ស្នើសុំសហចៅក្រមស៊ើបអង្កេតប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ឯកសារ A157 ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។

[19] ដីកាសម្រេចលើសំណើជាបន្ទាន់របស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D186/3។

[20] *ដូចយោងខាងលើ* កថាខណ្ឌ ៣៣។

01038573



ថា [redacted] *ក៏ពុំមានសិទ្ធិដាក់ពាក្យសុំមោឃភាព អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ដោយសារខ្វះសិទ្ធិ*[21]។

9. នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចលើសំណើរបស់ [redacted] ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់ឯកសារនានារបស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿងភ្ជាម ("ដីកាសម្រេចស្ដីពីការដាក់បញ្ចូលឯកសារ")[22]។ នៅក្នុងដីកាសម្រេចស្ដីពីការដាក់បញ្ចូលឯកសារ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទាញការចាប់អារម្មណ៍ទៅលើអង្គហេតុថា *ទាក់ទងនឹងពាក្យសុំ "សេចក្ដីសម្រេចផ្នែកតុលាការ បានធ្វើរួចហើយនៅក្នុងដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង គឺថា ជនសង្ស័យមិនមានសិទ្ធិដាក់សំណើបែបនោះឡើយ"*[23]។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចដាក់ពាក្យសុំនោះចូលទៅក្នុងផ្នែករដ្ឋបាល (ផ្នែក "ក") នៃសំណុំរឿង "ខណៈដែលរង់ចាំការប្រែប្រួលណាមួយទៅលើឋានៈរបស់ជនសង្ស័យ"[24]។

10. នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សំណើបន្ទាន់សុំការបញ្ជាក់បំភ្លឺទៅសហចៅក្រមស៊ើបអង្កេត ("សំណើសុំការបញ្ជាក់បំភ្លឺ")[25]។ នៅក្នុងសំណើសុំការបញ្ជាក់បំភ្លឺ មេធាវីការពារក្ដីកត់សម្គាល់ឃើញថា សេចក្ដីសម្រេចលើការចូលមើលសំណុំរឿង និងសេចក្ដីសម្រេចអំពីការដាក់ឯកសារ កំណត់ថា សេចក្ដីសម្រេចលើពាក្យសុំមោឃភាព ត្រូវបានធ្វើឡើងដោយបានធ្វើការបដិសេធពាក្យសុំដោយផ្អែកលើមូលដ្ឋានថា [redacted] គឺជាជនសង្ស័យ ដូច្នេះហើយ គាត់មិនមានសិទ្ធិដាក់ពាក្យសុំមោឃភាពនេះ ដោយបញ្ជាក់ថាវាមិនមានភាពច្បាស់

---

[21] *ដូចយោងខាងលើ* កថាខណ្ឌ ៣២។ សេចក្ដីសម្រេចនេះ ទាក់ទិននឹងសំណើសុំមោឃភាព កាលពីមុនរបស់ [redacted] ដែលបានដាក់ជាផ្នែកនៃសារណាស្ដីពីការពិចារណាសាជាថ្មី នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤។

[22] ដីកាសម្រេចលើសំណើរបស់ [redacted] ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់ឯកសារនានារបស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿងភ្ជាម ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D202/2។

[23] ដីកាសម្រេចស្ដីពីការដាក់បញ្ចូលឯកសារ កថាខណ្ឌ ១៤។

[24] ដីកាសម្រេចស្ដីពីការដាក់បញ្ចូលឯកសារ កថាខណ្ឌ ១៥។

[25] សំណើជាបន្ទាន់របស់ [redacted] សុំការបញ្ជាក់បំភ្លឺ ថាតើសេចក្ដីសម្រេចលើពាក្យសុំមោឃភាពរបស់គាត់ ត្រូវបានចេញរួចហើយ ឬមិនទាន់បានចេញនៅឡើយទេ ឯកសារ A157/1 ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤។

លាស់ថា តើមាន ឬមិនមានសេចក្តីសម្រេចជាក់លាក់មួយលើពាក្យសុំមោឃភាពដែលពួកគាត់ត្រូវការដឹងដើម្បីបន្តនីតិវិធីប្តឹងឧទ្ធរណ៍ដែរឬយ៉ាងណា[26]។

11. នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានឆ្លើយតបទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ ដោយកត់សម្គាល់ឃើញថា គាត់បានសម្រេចរួចហើយនៅក្នុងសេចក្តីសម្រេចអំពីការដាក់ឯកសារ ដូចដែលបានសម្រេចពីមុននៅក្នុងសេចក្តីលើការចូលមើលសំណុំរឿងថា "ជនសង្ស័យនានាមិនមានសិទ្ធិដាក់ពាក្យសុំអនុលោមតាមវិធានផ្ទៃក្នុង ៧៦ ឡើយ" ហើយបានបញ្ជាក់បំភ្លឺថា "ពាក្យសុំត្រូវបានបដិសេធមិនអាចទទួលយក" ("សេចក្តីសម្រេចដែលរងការជំទាស់")[27]។

12. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចលើការចូលមើលសំណុំរឿង ដែលសហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ បង្គាប់ទៅក.ស.ច.ស មេត្តាអនុញ្ញាតឱ្យមេធាវីការពារក្តីបានចូលពិនិត្យមើលសំណុំរឿងភ្លាម *និងមោឃៈកិច្ចស៊ើបសួររបស់ក.ស.ច.ស ចាប់ពីថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៤ រហូតដល់កាលបរិច្ឆេទដែលមេធាវីការពារក្តីត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ("បណ្តឹងឧទ្ធរណ៍លើការសុំចូលពិនិត្យមើលសំណុំរឿង")[28]។

13. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានជូនដំណឹងអំពីចេតនាចង់បណ្តឹងឧទ្ធរណ៍[29]លើសេចក្តីសម្រេចដែលរងការជំទាស់ និងនៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍។ មេធាវីការពារក្តីបានធ្វើលើកសំណើសុំឱ្យមានសវនាការលើបណ្តឹងឧទ្ធរណ៍នោះទេ និងមិនមានការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នៅក្នុងអំឡុងពេលនៃការកំណត់ពេលវេលាតាមផ្លូវច្បាប់នោះទេ។

---

[26] សំណើសុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ៨។

[27] ចម្លើយតបចំពោះពាក្យសុំបន្ទាន់របស់ [redacted] សុំការបំភ្លឺថាតើមានការចេញដីកាសម្រេចលើពាក្យសុំមោឃភាពរបស់គាត់ ឯកសារ A157/2 ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ៣។

[28] បណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះដីកាសម្រេចលើសំណើជាបន្ទាន់របស់គាត់ ដែលសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D186/3/1/1។

[29] ការចុះបញ្ជីបណ្តឹងឧទ្ធរណ៍អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយតបចំពោះពាក្យសុំបន្ទាន់របស់ [redacted] សុំការបំភ្លឺថាតើមានការចេញដីកាសម្រេចលើពាក្យសុំមោឃភាពរបស់គាត់ ឯកសារ A157/2/1 ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤។

14. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានចេញការពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើការចូលមើលសំណុំរឿង ("ការពិចារណាលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការចូលមើលសំណុំរឿង")[30]។ នៅក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការចូលមើលសំណុំរឿង អង្គបុរេជំនុំជម្រះបានប្រកាសថា "អង្គបុរេជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រពីចៅក្រមយ៉ាងតិចបួនសំឡេង ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះបានឡើយ"[31]។ អង្គបុរេជំនុំជម្រះបានលើកឡើងថា អង្គបុរេជំនុំជម្រះនៅតែ "មានការខ្វែងយោបល់គ្នាទៅលើបញ្ហាថាតើ *ម្ចាស់បណ្តឹងឧទ្ធរណ៍មានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤ និង ៧៦ នៃវិធានផ្ទៃក្នុងដែរឬទេ* ដោយសារថាគាត់មិនទាន់ត្រូវបានជូនដំណឹងជាផ្លូវការអំពីបទចោទប្រឆាំងនឹងរូបគាត់ អនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធាន៥៧ នៃវិធានផ្ទៃក្នុង"[32]។ ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការចូលមើលសំណុំរឿងនេះបាន វិធាន៧៧(១៣)នៃវិធានផ្ទៃក្នុងកំណត់ថា សេចក្តីសម្រេចលើការចូលមើលសំណុំរឿង ត្រូវតម្កល់ទុកជាបានការ[33]។

## បណ្តឹងឧទ្ធរណ៍

15. នៅក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះឱ្យទទួលយកបណ្តឹងឧទ្ធរណ៍ និងមោឃភាពកិច្ចស៊ើបសួរទាំងមូលដោយផ្អែកលើមូលដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ [redacted] នោះទេ[34]។ មេធាវីការពារក្តីលើកឡើងថាបណ្តឹងឧទ្ធរណ៍អាចទទួលយកបានផ្អែកតាមជម្រើសទាំងបី។

---

[30] ការពិចារណារបស់អង្គជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿងនិងចូលរួមក្នុងកិច្ចស៊ើបសួរ ឯកសារD192/1/1/2 និង D186/3/1/2 ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

[31] ដូចខាងលើ ផ្នែកសម្រេចសេចក្តី។

[32] ដូចខាងលើ កថាខណ្ឌ ៣១។

[33] ដូចខាងលើ កថាខណ្ឌ ៣៣។

[34] បណ្តឹងឧទ្ធរណ៍ សំណើសុំ។

16. ទីមួយ មេធាវីការពារក្ដីលើកឡើងថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានផ្អែកតាមវិធាន ៧៤(៣)(ឆ) ដោយសារតែនៅពេលដែលដាក់ពាក្យសុំមោឃភាព ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនទាន់ត្រូវបានពិចារណាសាជាថ្មីនោះទេ។ ហេតុដូច្នេះ បើតាមមេធាវីការពារក្ដី [redacted] ត្រូវបានយល់ឃើញ*តាមផ្លូវច្បាប់*ថាកំពុងចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដែលក្នុងនោះរួមមានការដាក់សំណើសុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនពាក្យសុំមោឃភាពទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន៧៦(២)នៃវិធានផ្ទៃក្នុង[35]។

17. ទីពីរ មេធាវីការពារក្ដីបន្ថែមថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានផ្អែកតាមវិធាន៧៤(៣)(ឆ) តាមរយៈការបកស្រាយទូលំទូលាយលើសិទ្ធិប្ដឹងឧទ្ធរណ៍របស់ [redacted] ក្រោមវិធាន២១ នៃវិធានផ្ទៃក្នុង ដែលវិធាននេះយកមកអនុវត្តចំពោះជនសង្ស័យផងដែរ។ បើតាមមេធាវីការពារក្ដីលើកឡើងសិទ្ធិរបស់ [redacted] ក្រោមមាត្រា១៤(១) នៃ ICCPR ត្រូវបានរំលោភបំពានដោយសារតែគាត់ត្រូវបានស៊ើបអង្កេតដោយតុលាការអសមត្ថកិច្ច[36]។

18. ជាចុងក្រោយ ផ្អែកតាមការលើកឡើងនូវសំអាងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ មេធាវីការពារក្ដីលើកទឡ្ហីករណ៍ថា ដោយសារតែបណ្ដឹងឧទ្ធរណ៍លើកឡើងនូវបញ្ហានៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ បណ្ដឹងឧទ្ធរណ៍គឺអាចទទួលយកបានផ្អែកតែលើមូលដ្ឋាននៃវិធាន២១នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ[37]។

19. យោងតាមមូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍ មេធាវីការពារក្ដីផ្ដល់ទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានការភាន់ច្រឡំនៅពេលសម្រេចថា ពាក្យសុំនេះមិនអាចទទួលយកបានដោយផ្អែកលើមូលដ្ឋាននៃ "*និយមន័យតឹងរ៉ឹង*ទៅលើអ្នកដែលអាចដាក់ពាក្យសុំមោឃភាព" ដោយមិនរាប់បញ្ចូលជនសង្ស័យ ដោយហេតុថា យោងតាមសេចក្ដីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្ដីនិយមន័យបែបនេះមិនបានពិចារណាលើសិទ្ធិជាសារវន្តរបស់ [redacted][38]។ ចំណុចទីពីរ ក្រុមមេធាវីការពារក្ដីអះអាងថា កិច្ចស៊ើបសួរត្រូវចាត់ទុកជាមោឃៈដោយហេតុថាវារំលោភលើសិទ្ធិ

[35] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[36] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨។

[37] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៩។

[38] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៦-២៩។

របស់ [redacted] ក្នុងការទទួលបានការស៊ើបអង្កេត និងការជំនុំជម្រះដោយ *តុលាការមានសមត្ថកិច្ច*[39]។ ចំណុចចុងក្រោយ យោងលើយុត្តិសាស្ត្រនៃអង្គបុរេជំនុំជម្រះ មេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍ថា "គេអាចទុកជាមោឃៈនូវកិច្ចស៊ើបសួរទាំងមូលបាន" និងស្នើសុំឱ្យមោឃភាពកិច្ចស៊ើបសួរ *ទាំងមូល*ចោល[40]។

## II. ការពិចារណា

20. បើទោះជាភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ត្រូវបានលើកទឡ្ហីករណ៍ផ្អែកតាមវិធាន ៧៤ និងវិធាន ៧៦ ឬ វិធាន ២១ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ករណី *ថាតើម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលជាជនសង្ស័យមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានសិទ្ធិដាក់ពាក្យសុំដែរឬអត់នោះ* គឺជាបញ្ហាសំខាន់នៃទឡ្ហីករណ៍ស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលពាក្យសុំ ឬ បណ្តឹងឧទ្ធរណ៍ទាំងនេះស្នើសុំអនុវត្តសិទ្ធិនីតិវិធីដូចជា៖ ១) ការដាក់ពាក្យសុំជូនសហចៅក្រមស៊ើបអង្កេតស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតដាក់ពាក្យសុំមោឃភាពទៅអង្គបុរេជំនុំជម្រះ និង ២) ដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ឬ សេចក្តីសម្រេចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេតដែលច្រានចោលពាក្យសុំបែបនេះ។

21. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហានៃសិទ្ធិដាក់ពាក្យសុំ ឬ បណ្តឹងឧទ្ធរណ៍ ឬ ថាតើពាក្យសុំត្រូវបានលើកឡើងសមស្របដែរឬទេនោះ "ធ្លាប់បានអង្គបុរេជំនុំជម្រះយកមកពិចារណានាពេលមុនរួចហើយ ហើយវាក៏ជាផ្នែកមួយនៃយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិផ្សេងទៀត" នៅក្នុងការ *ពិនិត្យអំពីភាពអាចទទួលយកបាន*សម្រាប់ពាក្យសុំផងដែរ"[41] ។

---

[39] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០-៥៩។

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦០-៦២។

[41] សេចក្តីសម្រេចលើពាក្យសុំពិចារណាឡើងវិញចំពោះសេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តី សុំព្យួរកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំវិធានការទាក់ទងនឹងការធ្វើជាតំណាងប្រកបដោយប្រសិទ្ធភាពចំពោះជនសង្ស័យនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ ៥ (បណ្តឹងឧទ្ធរណ៍លេខ អ.ប.ជ ០១) កថាខណ្ឌ ៤ ដែលបានយោងលើយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងអន្តរជាតិនាពេលមុនៗត្រង់បញ្ហានេះ។

22. អង្គបុរេជំនុំជម្រះមានការខ្វែងយោបល់គ្នាលើបញ្ហាថាតើម្ចាស់បណ្ដឹងឧទ្ធរណ៍មានសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធានផ្ទៃក្នុងដែរទេ ដោយហេតុថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំទាន់ត្រូវបានជូនដំណឹងជាផ្លូវការអំពីបទចោទដាក់បន្ទុកលើខ្លួន អនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុងនៅឡើយ។ ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ហួត វុទ្ធី និងចៅក្រម ន័យ ធុល សម្រេចថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលពុំទាន់ជា "ជនត្រូវចោទ" ឬ "ជនជាប់ចោទ" នៅឡើយ អនុលោមតាមវិធានផ្ទៃក្នុង មិនអាចដាក់បណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៤ វិធាន ៧៦ នៃវិធានផ្ទៃក្នុងនោះទេ។ ចំណែក ចៅក្រម CHUNG និងចៅក្រម DOWNING មានការបកស្រាយផ្សេង លើវិធាន ៧៤ និងវិធាន ៧៦ នៃវិធានផ្ទៃក្នុង ក្រោយពីពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយយល់ឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍មានសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍បាន ដោយហេតុថា អ្វីដែលជាបញ្ហាតវ៉ាជាក់លាក់គឺត្រង់ការបកស្រាយលើសញ្ញាណនៃ "ជនត្រូវចោទ" ដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់តែប៉ុណ្ណោះ។ ចៅក្រមទាំងពីរយល់ឃើញថា នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះ សិទ្ធិជាសារវ័ន្តរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ តម្រូវឲ្យផ្ដល់សិទ្ធិនីតិវិធីដូចគ្នាដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដូចសិទ្ធិនីតិវិធីដែលមានចែងសម្រាប់ជនត្រូវចោទ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះមានការខ្វែងយោបល់គ្នា និងមានការបកស្រាយដោយឡែករៀងៗខ្លួនលើបញ្ហានេះ ដែលជាបញ្ហាចម្បងនៅក្នុងបណ្ដឹងឧទ្ធរណ៍ទាំងនេះ។ ទោះបីជា មានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះពុំអាចរកបានសំឡេងចំនួន ៤ សំឡេងដែលជាសំឡេងភាគច្រើនលើសលប់ដើម្បីចេញសេចក្ដីសម្រេចមួយលើបណ្ដឹងឧទ្ធរណ៍នេះបានទេ[42]។

23. ដោយហេតុថា អង្គបុរេជំនុំជម្រះពុំអាចចេញសេចក្ដីសម្រេចមួយលើបណ្ដឹងឧទ្ធរណ៍នេះ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងកំណត់ថា សេចក្ដីសម្រេចដែលត្រូវបានជំទាស់នៅមាន សុពលភាពដដែល។

---

[42] ចំពោះចំនួនសរុបនៃការបកស្រាយ និងមតិយោបល់ខុសគ្នារបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះត្រង់បញ្ហានេះ សូមមើល៖ ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ឯកសារ D121/4/1/4 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ដែលសាធារណជនអាចមើលបាន។

01038579



## III. សេចក្ដីសម្រេច

### អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ៖

ប្រកាសជាឯកច្ឆន្ទថា អង្គបុរេជំនុំជម្រះពុំអាចរកសំឡេងភាគច្រើនលើសលប់យ៉ាងហោច ៤ សំឡេងពីក្នុងចំណោមចៅក្រម ដើម្បីចេញសេចក្ដីសម្រេចមួយលើបណ្ដឹងឧទ្ធរណ៍បាននោះទេ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្រភាគច្រើននេះ ត្រូវបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី** ២១ **ខែ** វិច្ឆិកា **ឆ្នាំ ២០១៤**

**ប្រធាន** | **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គិមសាន** Rowan DOWNING **ន័យ ធុល** Chang-ho CHUNG **ហួត វុទ្ធី**